Special Representative of the United
Nations Secretary General for
Human Rights in Cambodia

Représentant spécial du Secrétaire général
des Nations Unies pour les droits de
l'homme au Cambodge

ថ្ងៃទី ១ ខែមេសា ឆ្នាំ១៩៩៧

# សេចក្តីថ្លែងការណ៍
# របស់លោក ថូម៉ាស់ ហែមម៉ាប៊ឹក
# តំណាងពិសេស របស់លោកអគ្គលេខាធិការ អង្គការសហប្រជាជាតិ
# ទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំកម្ពុជា

ខ្ញុំមានសេចក្តីតក់ស្លុត និងកំហឹងយ៉ាងខ្លាំង ចំពោះការវាយប្រហារដោយគ្រាប់បែក ដ៏សែនឃោរឃៅ កាលពីថ្ងៃអាទិត្យ ទី ៣០ ខែ មិនា ឆ្នាំ ១៩៩៧ ដែលបានសម្លាប់មនុស្ស យ៉ាងហោចណាស់ ១៦ នាក់ និងធ្វើឲ្យរបួសជាង ១២០ នាក់ផ្សេងទៀត ក្នុងនោះរួមមាន សមាជិកគណបក្សជាតិខ្មែរ អ្នកកាសែត នាយប៉ូលីស និង អ្នកដំណើរ ។ ឃាតករ បាន បង្ហាញឲ្យឃើញនូវភាពមិនអើពើទាល់តែសោះ ចំពោះជីវិតជនស្លូតត្រង់ ហើយត្រូវតែបាន ផ្តន្ទាទោសយ៉ាងខ្លាំងក្លាបំផុត ដែលអាចធ្វើទៅបាន ។

នេះគឺជាការប៉ុនប៉ងដ៏ប្រត្យក្សមួយ ដើម្បីធ្វើឃាតអ្នកដឹកនាំគណបក្សនយោបាយ ប្រឆាំងមួយ ដែលបានដឹកនាំធ្វើបាតុកម្មនយោបាយស្របច្បាប់ និងដោយសន្តិវិធីមួយនោះ ។ ជនល្មើស និងអ្នកធានារ៉ាប់រងឲ្យការវាយប្រហារនេះ មិនថាពួកគេមានឋានៈ ឬខ្សែរយៈ ជាអ្វី ក៏ដោយ ត្រូវតែរកឲ្យឃើញ ចាប់ខ្លួនឲ្យបាន រួចកាត់ទោស និងផ្តន្ទាទោសតាមច្បាប់ នៃ ប្រទេសកម្ពុជា ។

ដោយមកពីការខ្វះខាតនូវការស៊ើបអង្កេតដ៏ត្រឹមត្រូវ និងការខកខានមិនបានបញ្ជូនទៅ តុលាការ នូវជនល្មើសដែលបានប្រព្រឹត្តអំពើហិង្សាដោយមូលហេតុនយោបាយកន្លងមកនោះ ក្នុងនោះរួមមាន ឃាតកម្មលើអ្នកកាសែត នួន ចាន់ កាលពីខែកញ្ញា ឆ្នាំ ១៩៩៤ ការវាយ ប្រហារដោយគ្រាប់បែក ទៅលើគេហដ្ឋានសម្តេច ស៊ីន សាន និងទៅលើអ្នកគាំទ្រលោក ដែលស្ថិតនៅក្នុងវត្តមួយក្បែរនោះ កាលពីខែកញ្ញា ឆ្នាំ ១៩៩៥ ការវាយកំទេចការិយាល័យ

Mr. Thomas Hammarberg
Stockholm : Rosenbad 4, P.O. Box 16121, S. 10323 Stockholm, Sweden
Tel: 0046-8-405 5646 Fax: 0046-8-723 1176
Phnom Penh : Centre For Human Rights, P.O. Box 108, Street 400, House 18, Phnom Penh, Cambodia
Tel: 855-23-362585/362797 Fax: 855-23-720030
E-mail: chrcambodia@pactok.peg.apc.org

របស់កាសែត «សេរីភាពថ្មី» កាលពីខែតុលា ឆ្នាំ ១៩៩៥ ឃាតកម្មលើអ្នកកាសែត ធន់ ប៊ុនលី កាលពីខែឧសភា ឆ្នាំ ១៩៩៦ ហើយនិងករណីផ្សេងទៀត បានធ្វើឲ្យខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំងក្លា ចំពោះលទ្ធភាពនៃការស៊ើបអង្កេតជាអាជីពមួយដ៏ហ្មត់ចត់ ចំពោះករណីនេះ ។ ខ្ញុំសូមអំពាវនាវដល់រាជរដ្ឋាភិបាល សូមឲ្យចូលពាក់ព័ន្ធដោយផ្ទាល់និងដ៏ពេញលេញ ដើម្បីធ្វើការស៊ើបអង្កេតមួយដ៏ត្រឹមត្រូវ និងហ្មត់ចត់ ចំពោះករណីនេះ ។

ខ្ញុំមានសេចក្តីព្រួយបារម្ភ ចំពោះការស្នើដែលថា ទិសដៅនៃការវាយប្រហារនេះ ពោលគឺលោក សម រង្ស៊ី គួរត្រូវបានចាប់ខ្លួន ព្រោះតែបានដឹកនាំធ្វើបាតុកម្មខុសច្បាប់មួយនោះ ។ បាតុកម្មនេះ បានត្រូវអនុញ្ញាតជាលាយល័ក្ខអក្សរ ដោយសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កាលពីថ្ងៃទី ២៩ ខែមិនា ឆ្នាំ ១៩៩៧ ស្របតាមច្បាប់ និងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។ សិទ្ធិធ្វើបាតុកម្មដោយសន្តិវិធី គឺជាសិទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សជាមូលដ្ឋានបំផុតមួយ ។ ផ្ទុយពីការដែលត្រូវបានជាទិសដៅ នៃការវាយប្រហារ ប្រកបដោយការបំផ្លាញជីវិតមនុស្សជាច្រើននេះ មនុស្សដែលបានចូលរួមបាតុកម្មមួយបែបនេះ ត្រូវតែបានទទួលការការពារពីសំណាក់នគរបាល ។ នេះគឺជាភារកិច្ច របស់រដ្ឋាភិបាល នៃសង្គមប្រជាធិបតេយ្យមួយ ដែលគោរពសិទ្ធិមនុស្ស ។

ខ្ញុំក៏មានការព្រួយបារម្ភផងដែរ ដែលថាការសម្លាប់រង្គាលនេះ ព្រមទាំងការវាយប្រហារគ្នា រវាងបក្សពួកផ្សេង ៗ នៅក្នុងខេត្តបាត់ដំបង នាពេលកន្លងមកនេះ ហើយនិងករណីជាច្រើនផ្សេងទៀតពាក់ព័ន្ធនិងអំពើហិង្សានយោបាយ ដែលមិនទាន់បានដោះស្រាយនោះ បានបង្កើតឲ្យមានបរិយាកាសមួយ ដែលនឹងធ្វើឲ្យការរៀបចំការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ ជួបការលំបាកកាន់តែច្រើនថែមទៀត ។ អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តដល់រាជរដ្ឋាភិបាល ព្រមទាំងគណៈបក្ស និងអ្នកដឹកនាំនយោបាយទាំងអស់ សូមឲ្យធ្វើយ៉ាងណាដើម្បីបញ្ចប់ឲ្យបាន នូវអំពើហិង្សា និងការបំភិតបំភ័យខាងនយោបាយ នៅក្នុងប្រទេសកម្ពុជា ហើយធានាឲ្យបាននូវសុវត្ថិភាព នៃជនកម្ពុជាទាំងអស់ ក្នុងការរួមចំណែកដ៏ពេញលេញ និងដោយសេរី ក្នុងជីវភាពនយោបាយនៃប្រទេសនេះ ។

ក្នុងទិសដៅនេះ ខ្ញុំសូមអំពាវនាវ ដល់អ្នកដឹកនាំនយោបាយទាំងអស់ សូមធ្វើឲ្យបានសំរេច នូវកិច្ចព្រមព្រៀងជាផ្លូវការមួយ ដើម្បីបោះបង់ចោលការប្រើអំពើហិង្សា ហើយនិង

ដាក់វិន័យដ៏តឹងរ៉ឹងបំផុត ដល់កងយោធា កងនគរបាល និងកងកម្លាំងប្រដាប់អាវុធទាំងអស់ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន ឲ្យគោរពនូវកិច្ចព្រមព្រៀងនេះ ។ បន្ទាប់ពីទទួលរងនូវសង្គ្រាម និងអំពើហិង្សា ដ៏ច្រើនឆ្នាំកន្លងមកនេះ ប្រជាពលរដ្ឋកម្ពុជាគួរណាស់តែត្រូវបានរស់នៅក្នុងបរិយាកាសមួយ ផុតពីអំពើហិង្សានយោបាយ និងការភ័យខ្លាច ។ មានតែអ្នកដឹកនាំនយោបាយកម្ពុជាប៉ុណ្ណោះទេ ដែលអាចធ្វើឲ្យការនេះអាចសំរេចទៅបាន ។

ជាទីបញ្ចប់ ខ្ញុំសូមសំដែងនូវសមានចិត្ត និងទុក្ខក្រៀមក្រម ដ៏ស្មោះបំផុត ជូនចំពោះអ្នករងរបួសទាំងឡាយ និងជូនចំពោះក្រុមគ្រួសារ នៃអ្នកដែលបានបាត់បង់ជីវិត ។ គេមិនអាចអនុញ្ញាត ឲ្យអំពើបែបនេះកើតមានបានទេ នៅក្នុងប្រទេសកម្ពុជា ឬនៅទីកន្លែងណាដ៏ទៃទៀតក៏ដោយ ។ សូមជឿជាក់ចុះថា ខ្លួនខ្ញុំផ្ទាល់ និងអង្គការសហប្រជាជាតិ នឹងធ្វើនូវអ្វី ៗ គ្រប់បែបយ៉ាងទាំងអស់ ក្នុងអំណាចរបស់ខ្លួន ដើម្បីធានាឲ្យបាន នូវការផ្តល់យុត្តិធម៌ចំពោះករណីនេះ ។